ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧ អយក. សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបើកដំណើរការឡើងវិញ
# គ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច
# ក្នុងដំណាក់កាលទី២

ក្រោយពីការដាក់ឱ្យអនុវត្តវិស្សមកាលតូចមុនកាលកំណត់ និងការដាក់ឱ្យបន្តវិស្សមកាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច បានបន្តអនុវត្តការបង្រៀននិងរៀនតាមការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាពីចម្ងាយតាមបែបប្រពៃណី ក្រោមការជួយគាំទ្ររបស់មាតាបិតា អ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូច។

ដើម្បីធានាថា ការបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សាមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច ក្នុងដំណាក់កាលទី២ មានប្រសិទ្ធភាព និងប្រកបដោយសុវត្ថិភាព ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូចតាមគ្រប់រូបភាព រួមទាំងមាតាបិតា អ្នកអាណាព្យាបាល ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការត្រៀមលក្ខណៈ និងការបើកដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូចឡើងវិញ ដូចខាងក្រោម៖

## ១-ការត្រៀមលក្ខណៈដើម្បីបើកដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូចឡើងវិញ

គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូចទាំងអស់ ត្រូវពិនិត្យលក្ខណៈសម្បត្តិរបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច ដូចតទៅ៖

- អនុវត្តតាម “**គោលការណ៍ប្រតិបត្តិស្តង់ដា សម្រាប់ដំណើរការសាលារៀនឡើងវិញ ក្នុងបរិបទកូវីដ-១៩ SOP**” ជាពិសេសវិធានការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល៖

**ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព**

  - ត្រូវអនុវត្តវិធានរម្ងាប់មេរោគ មុននឹងដាក់ឱ្យដំណើរការគ្រឹះស្ថានសិក្សា ជាពិសេសបន្ទប់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ អគារ សួនកំសាន្តរបស់កុមារ និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- ត្រូវរៀបចំធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារ និងបរិវេណគ្រឹះស្ថានសិក្សា និងត្រូវគ្រប់គ្រងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ។

**ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាគម្លាតសុវត្ថិភាពក្នុងគ្រឹះស្ថានសិក្សា**

- ត្រូវរៀបចំតុកៅអីអង្គុយសម្រាប់កុមារនៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច ២ ម៉ែត្រ និងរៀបចំចំណុះថ្នាក់ ដោយកំណត់កុមារមិនលើសពី ១៥ ទៅ ២០ នាក់ក្នុង១ថ្នាក់
- ត្រូវបើកច្រកទ្វារចេញចូលក្នុងបរិវេណគ្រឹះស្ថានសិក្សាទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើនកកកុញតាមច្រកចេញចូល ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី ១,៥ ម៉ែត្រឡើងទៅនៅច្រកទ្វារចូលគ្រឹះស្ថានសិក្សា
- ត្រូវបែងចែកវេនកុមារមួយចំនួននៅក្នុងបន្ទប់ និងមួយចំនួនចេញក្រៅបន្ទប់រៀន នៅពេលចេញលេងម្តងៗ ព្រមទាំងត្រូវជានាគម្លាតសុវត្ថិភាពពេលចូលប្រើប្រាស់បង្គន់អនាម័យ ឬកន្លែងលាងសម្អាតដៃ។

**ការលើកកម្ពស់សុខភាពចាំបាច់ដល់កុមារ បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀត**

- ត្រូវពិនិត្យលទ្ធភាពរៀបចំបន្ទប់សុខភាព និងចាត់តាំងឱ្យមានគ្រូទទួលបន្ទុកសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ សម្រាប់ការសង្គ្រោះបឋម ការពិនិត្យសុខភាពជូនកុមារ បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា
- ត្រូវណែនាំមាតាបិតា អ្នកអាណាព្យាបាល ផ្តល់ព័ត៌មានអំពីសុខភាព និងប្រវត្តិនៃការធ្វើដំណើរក្នុង និងក្រៅប្រទេស និងការជួបជុំដែលអាចបង្កើតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩
- ត្រូវចាត់វិធានការវាស់កម្តៅកុមារ បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សាជាប្រចាំ មុនពេលចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា។ករណីរកឃើញមានកម្តៅចាប់ពី ៣៧,៥ អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងគ្រឹះស្ថានសិក្សាឡើយ ហើយត្រូវណែនាំ និងអនុញ្ញាតឱ្យសម្រាកនៅផ្ទះ ឬទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព
- ត្រូវរៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចូលសាលា និងពេលចេញពីសាលា ដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់ និងពេលចេញរបស់បុគ្គលិកអប់រំ និងកុមារ ដើម្បីកុំឱ្យចូលនិងចេញក្នុងពេលតែមួយ ទាំងក្នុងបរិវេណគ្រឹះស្ថានសិក្សា និងពេលចូលក្នុងថ្នាក់រៀន។

**ការផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខារអនាម័យ**

- ត្រូវពិនិត្យលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតនៅក្នុងគ្រឹះស្ថានសិក្សា ជូនដល់កុមារ បុគ្គលិកអប់រំ និងលើកទឹកចិត្តឱ្យនាំយកទឹកស្អាតពីផ្ទះ សម្រាប់ទុកទទួលទានផ្ទាល់ខ្លួន
- ត្រូវរៀបចំបរិក្ខារលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ ឬក្បែរបន្ទប់រៀន ដោយមានសាប៊ូ និងមានទឹកស្អាតប្រើប្រាស់ជាប្រចាំ សមស្របតាមតម្រូវការរបស់កុមារ បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា
- ត្រូវពិនិត្យលទ្ធភាពរកទឹកសម្លាប់មេរោគដូចជា ទឹកអាល់កុល ឬទឹកដែលលាងសម្អាតដៃ សម្រាប់កុមារ បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សាបានប្រើប្រាស់ប្រចាំថ្ងៃ។

ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ-១៩

- ត្រូវណែនាំដល់កុមារ បុគ្គលិកអប់រំនិងបុគ្គលិកផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ស្តីពីសារៈសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ-១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថានសិក្សា
- ត្រូវធ្វើការហាមឃាត់បុគ្គលិកអប់រំ និងកុមារមិនឱ្យធ្វើដំណើរទៅកន្លែងមានអត្រាឆ្លងជំងឺកូវីដ-១៩ និងមិនត្រូវរៀបចំសកម្មភាពណាដែលបង្កឱ្យមានហានិភ័យនៃការចម្លងរោគ
- ត្រូវណែនាំដល់កុមារ បុគ្គលិកអប់រំ ឬបុគ្គលិកផ្សេងទៀតធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អកឬកណ្តាស់ដោយប្រើគន្លាក់កែងដៃ ឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ។

– បង្កើតគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា(សម្រាប់សាលាមត្តេយ្យសិក្សាដាច់ដោយឡែក)។ ចំពោះសាលាថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា មិនចាំបាច់បង្កើតទេ ដោយអនុវត្តរួមគ្នាជាមួយគណៈកម្មការគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សា។ ចំពោះគ្រឹះស្ថានសិក្សាដែលមានរចនាសម្ព័ន្ធគណៈ-កម្មការគ្រប់គ្រងរួចហើយ អាចរក្សាសមាសភាពដដែល ឬធ្វើបច្ចុប្បន្នកម្មបំពេញបន្ថែម (មណ្ឌលសុខភាព) ដើម្បីបន្តនិរន្តរភាព។ ចំពោះគ្រឹះស្ថានមត្តេយ្យសិក្សាទាំងឡាយណាដែលពុំទាន់បានបង្កើត ត្រូវរៀបចំសំណើសុំសេចក្តីសម្រេចពីរដ្ឋបាលឃុំ សង្កាត់។ សមាសភាពគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាមានសមាសភាពដូចខាងក្រោម៖

**ក- សម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ**

| | |
|---|---|
| – អាជ្ញាធរដែនដី(មេឃុំ ចៅសង្កាត់) | ជាប្រធាន |
| – តំណាងមណ្ឌលសុខភាព | ជាអនុប្រធាន |
| – នាយក នាយិកា សាលា | ជាអនុប្រធានប្រចាំការ |
| – តំណាងប៉ុស្តិ៍រដ្ឋបាល | ជាសមាជិក |
| – តំណាងព្រឹទ្ធាចារ្យ | ជាសមាជិក |
| – តំណាងគ្រូបង្រៀន | ជាសមាជិក |
| – តំណាងមាតាបិតា អ្នកអាណាព្យាបាល | ជាសមាជិក |

**ខ- សម្រាប់មត្តេយ្យសិក្សាសហគមន៍**

| | |
|---|---|
| – អាជ្ញាធរដែនដី(មេឃុំ ចៅសង្កាត់) | ជាប្រធាន |
| – តំណាងមណ្ឌលសុខភាព | ជាអនុប្រធាន |
| – តំណាងប៉ុស្តិ៍រដ្ឋបាល | ជាសមាជិក |
| – តំណាង គ.ក.ន.ក ឃុំ សង្កាត់ | ជាសមាជិក |
| – មេភូមិ | ជាសមាជិកប្រចាំការ |
| – គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ | ជាសមាជិក |
| – តំណាងមាតាបិតា អ្នកអាណាព្យាបាល | ជាសមាជិក |

ការសម្រេចបង្កើតគណៈកម្មការគ្រប់គ្រងសាលា ត្រូវចេញដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់ តាមរយៈសំណើរបស់នាយក នាយិកានៃគ្រឹះស្ថានមត្តេយ្យសិក្សា។

៦

គណៈកម្មការគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា/គណៈកម្មការទ្រទ្រង់គ្រឹះស្ថានមត្តេយ្យសិក្សា និង **អាជ្ញាធរដែនដីត្រូវ៖**

- ធ្វើយុទ្ធនាការផ្សព្វផ្សាយស្ដីពីការចូលរៀនឡើងវិញឱ្យបានទូលំទូលាយដល់មាតាបិតា និងអ្នកអាណាព្យាបាល
- ណែនាំមាតាបិតា អ្នកអាណាព្យាបាល ឱ្យយកចិត្តទុកដាក់លើការសិក្សារបស់កូន ជួយបង្រៀនកូនបន្ថែមនៅផ្ទះ ឬ បង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់កូន
- ពិនិត្យលទ្ធភាពស្វែងរកសម្ភារៈ ថវិកាដើម្បីជួយដល់គ្រឹះស្ថានមត្តេយ្យសិក្សា ក្នុងការលើកកម្ពស់ការបង្រៀននិងរៀន និងការកែលម្អបរិស្ថានគ្រឹះស្ថានមត្តេយ្យសិក្សា
- ពិនិត្យលទ្ធភាពវិភាជន៍ថវិកាមូលនិធិឃុំ សង្កាត់ ដើម្បីជួយដល់វិស័យអប់រំសាធារណៈនៅតាមមូលដ្ឋាន។

**មាតាបិតា អ្នកអាណាព្យាបាលត្រូវ៖**

- ជួយបង្រៀនកូន ឬ អង្គុយរៀនជាមួយកូន (សម្រាប់កុមារតូចៗ) ពន្យល់កូនបន្ថែម ចាំជួយលើកទឹកចិត្តកូន
- ផ្តល់ព័ត៌មាន ឬស្នើសុំជំនួយទៅគ្រូបង្រៀន គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា ឬអាជ្ញាធរដែនដី លើការជំរុញ និងលើកកម្ពស់ការសិក្សារបស់កូន
- អប់រំ និងណែនាំកូនចៅឱ្យថែរក្សាសុខភាព អនាម័យខ្លួនប្រាណ លាងសម្អាតដៃនឹងសាប៊ូឱ្យបានញឹកញាប់ និងត្រឹមត្រូវតាមគោលការណ៍ណែនាំ។

## ២- វិសាលភាពនៃការបើកដំណើរការឡើងវិញគ្រឹះស្ថានមត្តេយ្យសិក្សា និងសេវាអប់រំកុមារតូច

- គ្រឹះស្ថានសិក្សាមត្តេយ្យសិក្សាសាធារណៈ ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូចទាំងអស់ ស្ថិតក្នុងរដ្ឋបាលក្រុងនៃខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ត្រូវអនុវត្តការរៀនពេញលេញ គ្រប់កម្រិតថ្នាក់
- គ្រឹះស្ថានសិក្សាមត្តេយ្យសិក្សាសាធារណៈ ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូចទាំងអស់ដទៃទៀត (ក្រៅពីរដ្ឋបាលក្រុងនៃខេត្តទាំងបួនខាងលើ) ត្រូវអនុវត្តក្នុងទ្រង់ទ្រាយតូច ឆ្លាស់វេន និងកំណត់ចំនួនកុមារត្រឹម ១៥នាក់ ទៅ២០នាក់ ក្នុងមួយថ្នាក់ ព្រមទាំងផ្តល់អាទិភាពដល់កុមារអាយុ៥ឆ្នាំ។

## ៣- ការអនុវត្តកម្មវិធីសិក្សា

### ៣.១- ការអនុវត្តក្នុងឆមាសទី២ ឆ្នាំសិក្សា២០១៩-២០២០

គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូច (ស្ថិតក្នុងចំណុចទី២ ខាងលើ) ត្រូវបើកដំណើរការឡើងវិញ ចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ រហូតដល់ដំណាច់ខែវិច្ឆិកា ឆ្នាំ២០២០៖

- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងសេវាអប់រំកុមារតូចដទៃទៀត ក្នុងរដ្ឋបាលក្រុងនៃខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ត្រូវអនុវត្តកម្មវិធីសិក្សា

ក្នុងឆមាសទី២ ពេញលេញគ្រប់កម្រិតថ្នាក់

- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ ដទៃទៀត (ក្រៅពីរដ្ឋបាលក្រុងនៃខេត្តទាំង៤) ត្រូវបែងចែងម៉ោងបង្រៀននិងរៀនដែលមានកំណត់ក្នុងកម្មវិធីសិក្សា សម្រាប់មត្តេយ្យសិក្សានៅឆមាសទី២ លើមុខវិជ្ជាបុរេគណិត និងភាសាខ្មែរ តាមស្ថានភាពជាក់ស្តែង។

**៣.២- ការអនុវត្តឆ្នាំសិក្សា២០២០-២០២១**

ឆ្នាំសិក្សា ២០២០-២០២១ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ តទៅ ខ្លឹមសារអនុវត្តលម្អិតនឹងមានចែងក្នុងសេចក្តីណែនាំដំណើរការគ្រឹះស្ថានសិក្សាសាធារណៈឆ្នាំសិក្សា ២០២០-២០២១។

## ៤- ការរៀបចំកាលវិភាគសិក្សា

**៤.១- គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ**

- គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា បុគ្គលិកអប់រំ ត្រូវចូលរួមរៀបចំថ្នាក់រៀន និងបរិស្ថានគ្រឹះស្ថានមត្តេយ្យសិក្សា តាមវិធានសុវត្ថិភាពអនាម័យចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០
- ការចូលរៀនឡើងវិញត្រូវចាប់ផ្តើមចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០
- ថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ កម្រិតមធ្យម និងកម្រិតទាប ត្រូវបង្កើនម៉ោងសិក្សា ដោយផ្តោតលើមុខវិជ្ជាបុរេគណិតមានចំនួន ២ ម៉ោងសិក្សា ក្នុង១ថ្ងៃ និងភាសាខ្មែរ ៤ ម៉ោងសិក្សា ក្នុង១ថ្ងៃ តាមស្ថានភាពជាក់ស្តែង
- ការរៀបចំកាលវិភាគអាចបត់បែនទៅតាមភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន និងស្របតាមវេនកំណត់សម្រាប់ការបង្រៀននិងរៀន
- គ្រឹះស្ថានមត្តេយ្យសិក្សាដែលអនុវត្តកម្មវិធីបង្រៀននិងរៀនទ្រង់ទ្រាយតូច ត្រូវរៀបចំកាលវិភាគដោយអនុលោមតាមការបែងចែកវេនជាក់ស្តែង៖
  - *ថ្នាក់មត្តេយ្យសិក្សាកម្រិតទាប* ក្នុង១សប្តាហ៍ ត្រូវកំណត់យក ២ថ្ងៃ សម្រាប់កុមារមករៀនផ្ទាល់ជាមួយគ្រូនៅសាលារៀន និង ៣ថ្ងៃទៀត កុមារត្រូវរៀនពីចម្ងាយនៅតាមផ្ទះ ឬទីតាំងប្រមូលផ្តុំ ជាមួយមាតាបិតា អ្នកអាណាព្យាបាល តាមការកំណត់របស់គ្រឹះស្ថានមត្តេយ្យសិក្សា
  - *ថ្នាក់មត្តេយ្យសិក្សាកម្រិតមធ្យម* ក្នុង១សប្តាហ៍ ត្រូវកំណត់យក ២ថ្ងៃ សម្រាប់កុមារមករៀនផ្ទាល់ជាមួយគ្រូនៅសាលារៀន និង៣ថ្ងៃទៀត កុមាររៀនពីចម្ងាយនៅតាមផ្ទះ ឬទីតាំងប្រមូលផ្តុំ ជាមួយមាតាបិតា អ្នកអាណាព្យាបាល តាមការកំណត់របស់គ្រឹះស្ថានមត្តេយ្យសិក្សា
  - *ថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់* ក្នុង១សប្តាហ៍ ត្រូវកំណត់យក ៣ថ្ងៃ សម្រាប់កុមារមករៀនផ្ទាល់ជាមួយគ្រូនៅសាលារៀន និង២ថ្ងៃទៀត កុមាររៀនពីចម្ងាយនៅតាមផ្ទះ ឬទីតាំងប្រមូលផ្តុំ ជាមួយមាតាបិតា អ្នកអាណាព្យាបាល តាមការកំណត់របស់គ្រឹះស្ថានមត្តេយ្យសិក្សា
  - ចំពោះថ្នាក់ដែលត្រូវវេនរៀនពីចម្ងាយនៅតាមផ្ទះ គ្រូត្រូវរៀបចំសន្លឹកកិច្ចការតាមកាលវិភាគសម្រាប់ផ្តល់ឱ្យមាតាបិតា អ្នកអាណាព្យាបាលអនុវត្តជាមួយកូន។

**៤.២- ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍**

- គណៈកម្មការគ្រប់គ្រងថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងគ្រូបង្រៀន ត្រូវចូលរួមរៀបចំថ្នាក់រៀន និងបរិស្ថានគ្រឹះស្ថានថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ តាមវិធានសុវត្ថិភាពអនាម័យចាប់

ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

- ការចូលរៀនឡើងវិញត្រូវចាប់ផ្ដើមចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាត្រូវបង្កើនម៉ោងសិក្សា ដោយផ្តោតលើមុខវិជ្ជាបុរេគណិតមានចំនួន ២ម៉ោងសិក្សា ក្នុង១ថ្ងៃ និងភាសាខ្មែរ ៤ម៉ោងសិក្សា ក្នុង១ថ្ងៃ តាមស្ថានភាពជាក់ស្តែង
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលពុំទាន់មានលក្ខណៈស្តង់ដា ត្រូវបង្កើនម៉ោងសិក្សា ដោយផ្តោតលើមុខវិជ្ជាបុរេគណិតមានចំនួន ១ម៉ោងសិក្សា ក្នុង១ថ្ងៃ និងភាសាខ្មែរ ៣ម៉ោងសិក្សា ក្នុង១ថ្ងៃ តាមស្ថានភាពជាក់ស្តែង
- ការរៀបចំកាលវិភាគអាចបត់បែនទៅតាមភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន
- ក្នុង១សប្តាហ៍ ត្រូវកំណត់យក ២ថ្ងៃ សម្រាប់កុមារមករៀនផ្ទាល់ជាមួយគ្រូនៅថ្នាក់រៀន និង ៣ថ្ងៃទៀត កុមាររៀនពីចម្ងាយនៅតាមផ្ទះ ឬទីតាំងប្រមូលផ្តុំ ជាមួយមាតាបិតា អ្នកអាណាព្យាបាល
- ចំពោះការរៀនពីចម្ងាយនៅតាមផ្ទះ គ្រូត្រូវរៀបចំសន្លឹកកិច្ចការតាមកាលវិភាគសម្រាប់ផ្តល់ឱ្យមាតាបិតា អ្នកអាណាព្យាបាលអនុវត្តជាមួយកូន។

## ៥- ការបង្កើតទម្លាប់អនាម័យថ្មីនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា

- ចូលរួមក្នុងការសម្អាតគ្រឹះស្ថានសិក្សា និងកន្លែងផ្តល់សេវា មុនពេលបើកដំណើរការឡើងវិញ និងអនុវត្តប្រតិបត្តិការប្រចាំថ្ងៃ ដោយប្រើប្រាស់សាប៊ូ ទឹកអាល់កុល ឬជែលលាងដៃ ដោយត្រូវធានាការអនុវត្តតាមវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ និងការណែនាំប្រើប្រាស់របស់ផលិតផលទាំងនោះ (កុមារតូចមិនត្រូវចូលរួមក្នុងកិច្ចការសម្អាតទេ ដោយសារពួកគេងាយរងគ្រោះថ្នាក់)
- ណែនាំ ឬតម្រង់ទិសដល់កុមារ និងបុគ្គលិកអប់រំ អំពីវិធានអនាម័យ និងការយល់ដឹងអំពី រោគសញ្ញា និងផលប៉ះពាល់នៃជំងឺកូវីដ-១៩
- រៀបចំកន្លែងលាងសម្អាតដៃ និងផ្តល់សាប៊ូលាងដៃ ។ល។ និងធានាថាមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ការលាងសម្អាតដៃ
- សហការជាមួយមន្ត្រីសុខាភិបាល ដើម្បីវាស់សីតុណ្ហភាពរបស់កុមារ និងបុគ្គលិកអប់រំប្រចាំថ្ងៃ នៅច្រកចូល គ្រឹះស្ថានមត្តេយ្យសិក្សា ឬទីចាត់ការគ្រឹះស្ថានមត្តេយ្យសិក្សា ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូចដទៃទៀត
- បែងចែកថវិកា ឬកៀរគរថវិកាសម្រាប់ការទិញសាប៊ូលាងដៃ ទឹកអាល់កុល ឬជែលលាងដៃ ម៉ាស់ការពារ ស្រោមដៃ ។ល។
- រៀបចំឱ្យមានចំណតសមស្របនៅខាងក្រៅបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច ដើម្បីឱ្យមាតាបិតា អ្នកអាណាព្យាបាលជូនកូនមករៀន និងមកទទួលវិញ
- មុនចូលបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច បុគ្គលិកអប់រំ កុមារត្រូវពាក់ម៉ាស់ និងបន្តពាក់ក្នុងអំឡុងពេលសិក្សា (សម្រាប់កុមារ)
- នៅតាមក្លោងទ្វារ ឬច្រកចូលគ្រឹះស្ថានមត្តេយ្យសិក្សា ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូច ត្រូវរៀបចំឱ្យមានការវាស់កម្តៅ អាល់កុល ឬ ជែលលាងដៃ និងម៉ាស់

សម្រាប់កុមារដែលមិនមាន

- រៀបចំឱ្យមានការគោរពទង់ជាតិសម្រាប់តែបុគ្គលិកអប់រំ
- រៀបចំឱ្យមានគំនូសនៅតាមទីតាំងនៃការជួបជុំនានាក្នុងបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច ដើម្បីរក្សាបាននូវគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល
- កំណត់ចំនួនកុមារដែលប្រើប្រាស់បន្ទប់ទឹក ដោយមិនអនុញ្ញាតឱ្យចូលទាំងអស់គ្នានោះទេ
- មិនអនុញ្ញាតឱ្យមានការលក់ចំណីអាហារនៅក្នុងបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូចឡើយ(មាតាបិតា អ្នកអាណាព្យាបាលត្រូវរៀបចំអាហារនិងទឹកមកពីផ្ទះសម្រាប់កូនៗ)
- ជំរុញឱ្យមានការអប់រំសុខភាព អនុវត្តវិធីសាស្ត្រសុខភាពសិក្សា ផ្សព្វផ្សាយសារអប់រំសមស្របតាមអាយុនិងភាសា អំពីការលាងសម្អាតដៃ អនាម័យខ្លួនប្រាណ ការបង្ការជំងឺក្នុងគ្រឹះស្ថានមត្តេយ្យសិក្សា កន្លែងផ្តល់សេវាអប់រំកុមារតូច និងនៅក្នុងថ្នាក់រៀន
- កុមារ និងបុគ្គលិកសាលាត្រូវប្រើបាំងមុខ ឬពាក់ម៉ាស់ នៅក្នុងបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច និងក្នុងបន្ទប់រៀន និងលាងដៃឱ្យបានទៀងទាត់
- ជំរុញនិងលើកទឹកចិត្តឱ្យបង្កើតកម្មវិធីផលិតម៉ាស់នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច
- ផ្តល់ការគាំទ្រផ្នែកចិត្តសង្គមដល់កុមារ និងបុគ្គលិកអប់រំ ដើម្បីឱ្យពួកគេចេះទប់ទល់នឹងជំងឺបាក់ស្បាត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ ដូចជាការរស់នៅដាច់ដោយឡែក និងការរស់នៅក្នុងកន្លែងដែលមានការរាតត្បាត។ ពាក្យពេចន៍ ឬខ្លឹមសារគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រ ដល់គ្រូបង្រៀន និងបុគ្គលិកគ្រឹះស្ថានមត្តេយ្យសិក្សា ។ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការការពារ និងសុខុមាលភាពរបស់កុមារនៅក្នុងពេលបើកដំណើរការគ្រឹះស្ថានមត្តេយ្យសិក្សាឡើងវិញ
- ចំពោះបុគ្គលិក ឬកុមារដែលមានប្រវត្តិធ្វើដំណើរត្រឡប់ពីបរទេស ឬបានប៉ះពាល់ផ្ទាល់ក្នុងអំឡុងពេល ១៤ថ្ងៃ មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូចនោះទេ។ បុគ្គលិក ឬកុមារមានជំងឺផ្តាសាយធម្មតា ក៏មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូចដែរ។

## ៦- ការបង្រៀននិងរៀន

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ មត្តេយ្យសិក្សាសហគមន៍ និងកន្លែងផ្តល់សេវាអប់រំកុមារតូចទាំងអស់ត្រូវអនុវត្តដូចខាងក្រោម៖

- បន្តការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធផ្សព្វផ្សាយផ្លូវការ គឺត្រូវបន្តរៀបចំវីដេអូនៃសកម្មភាពការបង្រៀនតាមមុខវិជ្ជា និងតាមមេរៀនសម្រាប់មត្តេយ្យសិក្សាគ្រប់កម្រិតថ្នាក់ និងជំរុញការរៀនពីចម្ងាយតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការ ដូចជា Facebook, YouTube, TV ។ល។
- អនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ (ការសិក្សាក្នុងថ្នាក់រៀន និងការសិក្សាពីចម្ងាយតាមបែបប្រពៃណី ឬការប្រើប្រាស់សន្លឹកកិច្ចការជំនួយ)
- ត្រូវពិគ្រោះយោបល់ជាមួយគ្រូបង្រៀន ដើម្បីធ្វើវង្វាយតម្លៃការរៀនសូត្ររបស់កុមារ ឆ្ពោះទៅកំណត់មេរៀន ដែលត្រូវចាប់ផ្តើមបន្តបង្រៀន

- ត្រូវរៀបចំថ្នាក់រៀនឱ្យមានបរិយាកាសល្អសមស្របតាមគោលការណ៍ណែនាំ និងកំណត់ចំនួនកុមារត្រឹម១៥នាក់ ទៅ២០នាក់ ក្នុង១ថ្នាក់ ក្នុងករណីគ្រឹះស្ថានមត្តេយ្យសិក្សាពុំមានបន្ទប់រៀនគ្រប់គ្រាន់តាមតម្រូវការ ត្រូវកំណត់បែងចែកវេនសិក្សា ២ ឬ៣ថ្ងៃ ក្នុង ១សប្តាហ៍ និងអនុវត្តកម្មវិធីបង្រៀននិងរៀនទ្រង់ទ្រាយតូច
- គ្រូបង្រៀនតាមថ្នាក់នីមួយៗត្រូវគ្រប់គ្រងនិងតាមដានគ្រប់សកម្មភាពរបស់កុមារទាំងក្នុង និងក្រៅថ្នាក់រៀន និងមិនឱ្យលេងឆ្លងពីថ្នាក់រៀនមួយទៅថ្នាក់រៀនមួយទៀត
- គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាទាំងអស់ត្រូវអនុវត្តនិងរៀបចំការធ្វើតេស្តវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍសិក្សារបស់កុមារអាយុ ៥ឆ្នាំ ទៅតាមការណែនាំដែលបានកំណត់រួចមកហើយ។

## ៧. ការគាំទ្រ និងអន្តរាគមន៍ផ្សេងៗ

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ដូចជាផ្តល់ការរៀនសូត្រពីចម្ងាយ តាមរយៈ វីដេអូបង្រៀនដែលបានផ្សព្វផ្សាយនាពេលកន្លងមក
- គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា លោកគ្រូ អ្នកគ្រូ ត្រូវលើកទឹកចិត្តកុមារឱ្យបានចូលរៀន និងចូលរួមរៀនសូត្រ
- វាយតម្លៃលើផលប៉ះពាល់នៃការសិក្សា និងកំណត់ចំណុចខ្វះខាតដែលកុមារជួបប្រទះក្នុងការរៀនសូត្រ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមកុមារងាយរងគ្រោះ
- អនុវត្តយុទ្ធសាស្ត្របំប៉ន និងអនុវត្តថ្នាក់ពន្លឿនការសិក្សាឱ្យបានសមស្រប ដោយធ្វើយ៉ាងណាឱ្យធានាបាននូវគុណភាព សមភាព និងបរិយាបន្ន
- បន្តលើកទឹកចិត្តកុមារដែលងាយរងគ្រោះ តាមរយៈការផ្តល់ការគាំទ្រជាសម្ភារសិក្សា សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងទៀត
- អនុញ្ញាតបន្តឱ្យកុមារខ្ចីសៀវភៅសិក្សាគោល សៀវភៅរឿងខ្លីៗ និងឯកសារពាក់ព័ន្ធនឹងការរៀនសូត្រដើម្បីបានធ្វើស្វ័យសិក្សានៅផ្ទះ
- ជ្រើសរើសគ្រូបង្រៀនស្ម័គ្រចិត្តដើម្បីជួយបង្រៀនកុមាររៀនយឺត តាមរយៈការបំប៉នបន្ថែម
- បន្តគាំទ្រដល់កុមាររៀនយឺត ផ្អែកតាមលទ្ធផលតេស្តវាយតម្លៃ និងរៀបចំក្រុមកុមាររៀនយឺតសម្រាប់ការបង្រៀនបន្ថែម
- រៀបចំកាលវិភាគសិក្សា ដើម្បីធានាយ៉ាងណាឱ្យកុមាររៀនយឺតអាចរៀនសូត្រពេញមួយសប្តាហ៍
- រៀបចំការបង្រៀនបន្ថែម ការជួយបង្រៀនផ្ទាល់ សកម្មភាពរៀនសូត្រក្រៅប្រព័ន្ធ អប់រំបរិយាបន្ន អប់រំពហុភាសា និងអប់រំពិសេសបន្ថែមលើកម្មវិធីសិក្សាផ្លូវការ
- បន្តចែកសន្លឹកកិច្ចការឱ្យកុមារយកទៅធ្វើនៅផ្ទះ និងយកចិត្តទុកដាក់លើការវាយតម្លៃការសិក្សារបស់កុមារ ប្រមូល ត្រួតពិនិត្យ/កែកិច្ចការ និងផ្តល់ព័ត៌មានត្រឡប់ដល់កុមារជាប្រចាំ
- បន្តទំនាក់ទំនងល្អជាមួយមាតាបិតា អ្នកអាណាព្យាបាល ដោយផ្តល់ព័ត៌មានអំពីការសិក្សា របស់កូនទៅពួកគាត់ជាប្រចាំ។

## ៨. ការចុះត្រួតពិនិត្យ អធិការកិច្ច និងរបាយការណ៍

### ៨.១ ករណីបុគ្គលិកសិក្សា គ្រូបង្រៀន ឬកុមារមានកម្តៅខ្ពស់

- ករណីមានការពិនិត្យឃើញថា បុគ្គលិកសិក្សា គ្រូបង្រៀន ឬកុមារមានកម្តៅលើសពី ៣៧,៥ អង្សាសេ អ្នកទាំងនោះមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណសាលា ឬបន្ទប់រៀននោះទេ ហើយត្រូវសហការជាមួយអាជ្ញាធរសុខាភិបាល ដើម្បីទៅរកសេវាព្យាបាលសមស្រប
- **"គណៈកម្មការគ្រប់គ្រងសាលារៀន"** ត្រូវជូនដំណឹងដល់ មន្ទីរសុខាភិបាលជាបន្ទាន់ ឬតាមរយៈលេខទូរសព្ទទាន់ហេតុការណ៍ ១១៥ ក្នុងពេលមានការរកឃើញករណីសង្ស័យមានជំងឺកូវីដ-១៩។

### ៨.២ ការរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល

- សហការជាមួយអាជ្ញាធររដ្ឋបាលមូលដ្ឋាន និងមណ្ឌលសុខភាព (ដែលនៅជិត) ដើម្បីកំណត់យន្តការតាមដាន ត្រួតពិនិត្យជាប្រចាំអំពីប្រជាជនចំណូលថ្មី និងចាត់វិធានការការពារ ទប់ស្កាត់ និងឆ្លើយតបចំពោះហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ ព្រមទាំងផ្តល់ព័ត៌មានស្តីពីស្ថានភាពសុខភាពរបស់ប្រជាជនទូទៅក្នុងរដ្ឋបាលមូលដ្ឋាន ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ស្នើសុំមណ្ឌលសុខភាពឱ្យចាត់តាំងជនបង្គោលប្រចាំការ ដើម្បីងាយស្រួលទាក់ទងគ្នាចូលរួមអង្កេត និងអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងរក្សាអនាម័យរបស់គ្រឹះស្ថានមត្តេយ្យសិក្សា តាមការណែនាំរបស់ក្រសួងសុខាភិបាល
- សហការជាមួយដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល (ដូចជា ស.ស.យ.ក.) ដើម្បីស្វែងរកការជួយគាំទ្រផ្សេងៗ ដូចជា ការបង្រៀនបន្ថែម គ្រូស្ម័គ្រចិត្ត និងការគាំទ្រការសិក្សាពីចម្ងាយ ឬការចែកសន្លឹកកិច្ចការ សម្រាប់ដំណើរការបង្រៀននិងរៀនផ្ទាល់នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា និងនៅតាមផ្ទះ។

### ៨.៣ ការធ្វើអធិការកិច្ច

- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចជារួម
- មណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត ត្រូវចុះជួយជំរុញការអនុវត្តវិធានអនាម័យ និងគោលការណ៍ប្រតិបត្តិស្តង់ដា និងធ្វើអធិការកិច្ចសុខភាពសាធារណៈ នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា ឬកន្លែងផ្តល់សេវាអប់រំកុមារតូច
- ថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យនិងអធិការកិច្ច ដើម្បីផ្តល់ការគាំទ្រនិងកែលម្អជាប្រចាំ នៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច។

### ៨.៤ ការធ្វើរបាយការណ៍

- គណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំយន្តការចុះសម្របសម្រួលនិងពិនិត្យតាមដានសភាពការណ៍ទូទៅលើដំណើរការបង្រៀននិងរៀន នៃគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច
- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបន្តចុះជួយលើដំណើរការផ្នែកបច្ចេកទេសបង្រៀននិងរៀននៅគ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងឯកជន និងកន្លែងផ្តល់

សេវាអប់រំកុមារតូច

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពង្រឹង និងបង្កើនការអនុវត្តតួនាទី និងជំរុញសកម្មភាពការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការតាមដានគ្រប់ដំណើរការនៃគ្រឹះស្ថានមត្តេយ្យសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូច ទាំងផ្នែករដ្ឋបាល និងបច្ចេកទេសបង្រៀន និងរៀន
- គ្រប់គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃដំណើរការរបស់គ្រឹះស្ថានមត្តេយ្យសិក្សារួចបញ្ជូនមកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបូកសរុបរបាយការណ៍វឌ្ឍនភាពសម្រាប់មត្តេយ្យសិក្សា រួចបញ្ជូនមក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវបូកសរុបរបាយការណ៍វឌ្ឍនភាព ស្តីពីការបង្រៀននិងរៀន ជាធម្មតាតាមគន្លងថ្មីសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សា រួចបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់របាយការណ៍តាមឋានានុក្រមរៀបចំ ត្រូវចម្លងជូនទៅអាជ្ញាធររដ្ឋបាល (រដ្ឋបាលសាលាឃុំ សង្កាត់ រដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលសាលារាជធានី ខេត្ត)។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាគ្រប់កម្រិត បុគ្គលិកអប់រំ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

  **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអប់រំកុមារតូច